ព្រះរាជក្រឹត្យ

នស/រកត/០៨០៤/២៣៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.-

មាត្រា ១ និងមាត្រា ២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវបានកែតម្រូវដូចខាងក្រោម :

មាត្រា ១ថ្មី.-

បង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយហៅកាត់ថាគ.ជ.គ.ម និងជាអក្សរឡាតាំង ហៅកាត់ថា NCDM មានសមាសភាពដូចតទៅ :

១- នាយករដ្ឋមន្ត្រី	ប្រធាន
២- ឥស្សរជនជាន់ខ្ពស់មួយរូប	អនុប្រធានទី១
៣- ឥស្សរជនជាន់ខ្ពស់មួយរូប	អនុប្រធានទី២
៤- រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ	អនុប្រធាន

៥- រដ្ឋមន្ត្រី ក្រសួងការពារជាតិ	អនុប្រធាន
៦- រដ្ឋមន្ត្រី ទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៧- រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៨- រដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
៩- រដ្ឋមន្ត្រី ក្រសួងបរិស្ថាន	សមាជិក
១០- រដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម	សមាជិក
១១- រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
១២- រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម	សមាជិក
១៣- រដ្ឋមន្ត្រី ក្រសួងសុខាភិបាល	សមាជិក
១៤- រដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ	សមាជិក
១៥- រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
១៦- រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	សមាជិក
១៧- រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន	សមាជិក
១៨- រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
១៩- រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី	សមាជិក
២០- តំណាង អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ	សមាជិក
២១- តំណាងប្រធានសមាគមជាតិកាកបាទក្រហមកម្ពុជា	សមាជិក
២២- រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល	សមាជិក

មាត្រា ២ថ្មី.-

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានភារកិច្ចដូចតទៅ :

ក- អង្កេត តាមដាន វាយតំលៃ ប្រមូល វិភាគ គ្រប់គ្រងទិន្នន័យគ្រោះភ័យនៃគ្រោះមហន្តរាយ និងរៀបចំចងក្រងរបាយការណ៍ស្តីពីស្ថានភាពគ្រោះមហន្តរាយ ដើម្បីផ្តល់យោបល់ជូនរាជរដ្ឋាភិបាលដាក់ចេញនូវគោលការណ៍ គោលនយោបាយ សារាចរ សេចក្តីប្រកាស និងវិធានការសំរាប់ការគ្រប់គ្រងគ្រោះមហន្តរាយ

ខ- លើកសំណើជូនរាជរដ្ឋាភិបាលអំពីតម្រូវការ និងការប្រើប្រាស់ប្រភពធនធាន ដូចជាមូលនិធិ សម្ភារៈប្រេងឥន្ធនៈ មធ្យោបាយប្រើប្រាស់ និងធនធានមនុស្សដើម្បីដំណើរការកិច្ចប្រតិបត្តិការការងារគ្រប់គ្រងគ្រោះមហន្តរាយ និងសំរាប់ជួយដល់ជនរងគ្រោះដែលប៉ះពាល់ពីមុខសញ្ញាគ្រោះថ្នាក់ដោយធម្មជាតិ និងដោយមនុស្ស

គ- អភិវឌ្ឍធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលបច្ចេកទេសជំនាញ និងចំណេះដឹងដល់មន្ត្រីទទួលបន្ទុកការងារគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ជាតិ ក្រសួងពាក់ព័ន្ធ ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ សង្កាត់ ភូមិ និងអប់រំផ្សព្វផ្សាយការយល់ដឹងសាធារណៈដល់ប្រជាពលរដ្ឋ នៅសហគមន៍អំពីគ្រោះភ័យនៃគ្រោះមហន្តរាយដោយធម្មជាតិ និងដោយមនុស្ស

ឃ- សហការជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ព្រមទាំងសប្បុរសជន ដើម្បីអនុវត្តគោលនយោបាយជាតិ នៃការងារគ្រប់គ្រងគ្រោះមហន្តរាយ មានដូចជាការត្រៀមបង្ការ ការសំរាល ការត្រៀមរៀបចំ ដើម្បីទប់ទល់ទៅនឹងមុខសញ្ញាគ្រោះថ្នាក់ដោយធម្មជាតិ និងដោយមនុស្ស

ង- ធ្វើការទំនាក់ទំនង សំរបសំរួលកិច្ចសហប្រតិបត្តិការថ្នាក់ជាតិ ថ្នាក់តំបន់ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការផ្តល់ព័ត៌មានអោយគ្នាទៅវិញទៅមកអំពីស្ថានភាព និងស្ថានការណ៍ គ្រោះមហន្តរាយ សំដៅកាត់បន្ថយផលប៉ះពាល់ពីគ្រោះមហន្តរាយ

ច- ធ្វើការសំរបសំរួលជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល សហគមន៍អន្តរជាតិ និងសប្បុរសជនក្នុងស្រុក ដើម្បីកៀរគរស្វែងរកជំនួយសំរាប់ឆ្លើយតប សង្គ្រោះបន្ទាន់ និងស្តារឡើងវិញរាល់ការខូចខាតដោយគ្រោះមហន្តរាយ ។

មាត្រា ២.-

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសប្តាហ៍
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣រស.០៤០៧.២៣៧

លេខ: ១៩៦ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
សុខ ចាន់